**គោលនយោបាយ និងកម្មវិធី OFI មានការផ្លាស់ប្តូរជាបណ្តោះអាសន្ន ដោយសារបញ្ហាជំងឺ COVID 19 P.L. 116-159, P.L. 116-260, ឬ P.L. 117-2**
**បានបង្កើតឡើងនៅថ្ងៃទី 6 ខែមេសា ឆ្នាំ 2020**
**បានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2021**

**SNAP – កម្មវិធីជំនួយអាហារបង្គ្រប់ (Food Supplement Program) – ជំនួយអាហារូបត្ថម្ភ**

- ចាប់ផ្តើមពីខែមេសា ឆ្នាំ 2020 រហូតដល់ពេលជូនដំណឹងបន្ថែម គ្រួសារណាដែលបានកំណត់ថវិកា យ៉ាងហោចណាស់ $1 នឹងអាចទទួលបានយ៉ាងហោចណាស់ ជំនួយកម្រិតអប្បរមា សម្រាប់ទំហំគ្រួសាររបស់ពួកគេ ។
- ចាប់ផ្តើមពីខែឧសភា ឆ្នាំ 2021 រហូតដល់ពេលជនដំណឹងជាក្រោយ គ្រួសារដែលកំណត់ថវិកាយ៉ាងហោចណាស់ $1 នឹងអាចទទួលបានយ៉ាងហោចណាស់ $95 ច្រើនជាងការកំណត់ថវិកាជំនួយរបស់ខ្លួន ។
- គ្រួសារដែលទទួលបានជំនួយជាអតិបរមា ឬដែលទទួលបានជំនួយអប្បរមា នឹងទទួលបានការឡើង 15% នៃជំនួយសម្រាប់ខែមករា ដល់ខែកញ្ញា 2021 ។ គ្រួសារទាំងអស់ដែលទទួលបានជំនួយ ក្នុងរវាងកម្រិតអប្បរមា និងអតិបរមា នឹងទទួលបានការតម្លើងជំនួយខ្ពស់ ។
- ពាក្យសុំ លិខិតបញ្ជាក់ភាពមានសិទ្ធិទទួលជំនួយឡើងវិញ និងរបាយការណ៍ប្រាំមួយខែ អាចចុះហត្ថលេខាតាមទូរស័ព្ទបាន ។
- ជំនួយបង្គ្រប់សម្រាប់អ្នកធ្វើការ (Worker Supplement Benefit, WSB) ត្រូវបានកើនពី $50 ទៅ $100 ក្នុងមួយខែ រហូតដល់ខែមីនា ឆ្នាំ 2022 ។
- ការសម្ភាសន៍ សម្រាប់ការដាក់ពាក្យ និងសម្រាប់ការស្នើសុំបញ្ជាក់ភាពមានសិទ្ធិទទួលជំនួយឡើងវិញ នឹងមិនបាច់ធ្វើឡើយ រហូតដល់ពេលជូនដំណឹងជាក្រោយ ប្រសិនបើមិនមានតម្រូវការដើម្បីធ្វើការបញ្ជាក់ទេនោះ ។
- ចំពោះសិស្សដែលទទួលបានជំនួយថវិកាពីសហព័ន្ធចំពោះការរៀន និងធ្វើការ ឬអ្នកដែលមានប្រាក់វិភាគទានគ្រួសារប៉ាន់ស្មាន (Estimated Family Contribution, EFC) ចំនួន $0 ក្នុងមួយ គោលការណ៍ណែនាំនៃរូបមន្ត EFC ប្រហែលអាចមានសិទ្ធិទទួលបានជំនួយអាហារបន្ថែម ។

- យើងខ្ញុំកំពុងតែធ្វើការជាមួយនឹងក្រសួងសិក្សាធិការ (DOE, Deparment of Education) ដើម្បីឈានទៅរកការផ្តល់ជូនជំនួយ P-EBT រដូវក្តៅ (Summer P-EBT) ។ នេះគឺជាជំនួយស្បៀងអាហារ ជាប្រាក់ចំនួន $375 សម្រាប់សិស្សម្នាក់ៗដែលមានសិទ្ធិទទួលបានជំនួយនេះ ហើយយើងខ្ញុំមានគម្រោងថានឹងបើកជូននៅក្នុងខែតុលា ។ អាស្រ័យលើម៉ូដែលការបង្រៀនរបស់សាលា យើងខ្ញុំអាចនឹងបើកជំនួយ P-EBT សម្រាប់ឆ្នាំសិក្សា 2021-2022 ។ ពេលណាមានព័ត៌មានថ្មីៗ យើងខ្ញុំនឹងផ្សាយនៅនៅឯ https://www.maine.gov/dhhs/ofi/programs-services/food-supplement ។

**កម្មវិធី MaineCare – Medicaid - ជំនួយវេជ្ជសាស្ត្រ**

- ការធានារ៉ាប់រងមួយភាគធំរបស់កុមារ ឬមនុស្សពេញវ័យ នឹងនៅតែបើកចំហក្នុងអំឡុងពេលមានអាសន្នសុខភាពសាធារណៈ ។
- ការផ្ទៀងផ្ទាត់ដោយផ្ទាល់មាត់ (ការបញ្ជាក់ដោយខ្លួនឯង) គឺត្រូវបានអនុញ្ញាតសម្រាប់ភាពតម្រូវមួយភាគធំ ។
- មិនបាច់បង់បុព្វលាភរ៉ាប់រង ចំពោះកម្មវិធីធានារ៉ាប់រងសុខភាពដែលត្រូវបង់បុព្វលាភរ៉ាប់រង ។

**TANF – ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត (Temporary Assistance for Needy Families) – ជំនួយសាច់ប្រាក់ដល់គ្រួសារខ្វះខាត**

- មិនតម្រូវឲ្យអ្នកដាក់ពាក្យត្រូវចូលខ្លួនមកសម្ភាសន៍ដោយផ្ទាល់ឡើយ បើសិនជាសាមីខ្លួនជាអ្នកដាក់ពាក្យ មិនស្នើសុំទេនោះ ។

**ការក្រើនរំឭកសំខាន់ៗ**

- លេខទូរស័ព្ទផ្តល់ជំនួយទូទៅសម្រាប់ហេតុការណ៍បន្ទាន់ **1-800-442-6003 ។**
- ជានិច្ចកាល  អ្នកទទួលផលរបស់កម្មវិធី SNAP អាចឲ្យអ្នកដទៃដែលខ្លួនជឿជាក់ ប្រើប្រាស់ប័ណ្ណ EBT របស់ខ្លួន ដើម្បីទិញគ្រឿងទេស សម្រាប់គ្រួសាររបស់ពួកគេដែលជាអ្នកទទួលផលពីកម្មវិធី SNAP ។ គឺបុគ្គលនោះគ្រាន់តែត្រូវមានប័ណ្ណ និងលេខសម្ងាត់ប៉ុណ្ណោះ ។
- សូមធ្វើការទំនាក់ទំនងជាមួយ OFI តាមអនឡាញ ឬតាមទូរស័ព្ទ ហើយរាយការណ៍អំពីអ្វីៗដែលមានការប្រែប្រួលចំពោះស្ថានភាពគ្រួសាររបស់អ្នក នៅពេលដែលការប្រែប្រួលទាំងនោះកើតឡើង ។

សម្រាប់ព័ត៌មានបន្ថែមអំពីការទំនាក់ទំនងជាមួយនឹង OFI, ជម្រើសចំពោះការដាក់ពាក្យ និងព័ត៌មានបច្ចុប្បន្នភាពចុងក្រោយអំពីកម្មវិធី សូមចូលមកកាន់៖
**www.maine.gov/dhhs/ofi**

សម្រាប់ព័ត៌មានបន្ថែមអំពីនាយកដ្ឋានសេវាកម្មសុខភាព និងពលរដ្ឋ (Department of Health and Human Services) ស្តីអំពីធនធានព័ត៌មានវីរុសកូរ៉ូណា  សូមចូលមកកាន់៖
**www.maine.gov/dhhs/coronavirus-resources.shtml**

ឯកសារនេះនឹងមានការធ្វើបច្ចុប្បន្នភាព ។ សូមត្រឡប់មកកាន់ទំព័រនេះជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ។